# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦១៩ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុល

## ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងតភ្ជាប់ផ្លូវដែកសិង្ហបុរី-គុនមីញ
- យោងតាមលិខិតគោលនយោបាយដែលបានដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៦ និងអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគម្រោងស្តារជួសជុលឡើងវិញផ្លូវដែកនៅកម្ពុជា ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈកម្មាធិការតម្រង់ទិសសម្រាប់ និងក្រុមការងារសម្រាប់អនុវត្តគម្រោងជួសជុលស្តារផ្លូវដែកកម្ពុជាឡើងវិញ ដោយឥណទានថវិកាកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រុមការងារនេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ហើយត្រូវមានបុគ្គលិក រចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ខ្លួន ស្របទៅតាមគោលការណ៍ដែលបានឯកភាពជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២.-**

សមាសភាពនៃគណៈកម្មាធិការតម្រង់ទិស ត្រូវបានយកសមាសភាពក្នុងមាត្រា ២ ជំពូកទី ២ នៃអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងតភ្ជាប់ផ្លូវដែកសិង្ហបុរី-គុនមីញ។

**មាត្រា ៣.-**

បង្កើតក្រុមការងារគ្រប់គ្រងសម្បទាន នៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីគ្រប់គ្រងការងារលទ្ធកម្មសម្បទាន និងទំនាក់ទំនងរវាងក្រុមហ៊ុនប្រតិបត្តិកររាជាយស្វ័យយានក្នុងអាណត្តិសម្បទាន។ ក្រុមការងារគ្រប់គ្រងសម្បទានត្រូវរាយការណ៍ជូន និងទទួលខុសត្រូវលើការងាររបស់ខ្លួនចំពោះមុខរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរាជរដ្ឋាភិបាល។ សមាជិកទាំងអស់ត្រូវបំពេញការងារដោយឯករាជ្យ អព្យាក្រឹត្យ និងរក្សាការសម្ងាត់ ដោយមិនចាំបាច់ស្វែងរក ឬ ទទួលការណែនាំពីខាងក្រៅលើការងាររបស់ខ្លួនឡើយ។ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិអញ្ជើញបុគ្គលដែលមានការពាក់ព័ន្ធដើម្បីផ្តល់ព័ត៌មាន ឬយោបល់ដល់ក្រុមការងារគ្រប់គ្រងសម្បទានតាមការចាំបាច់។ ក្រុមការងារគ្រប់គ្រងសម្បទាន មានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម អ៊ុក ចាន់ រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន

| | | |
|---|---|---|
| ២- ឯកឧត្តម **ទង្សី ទិសុវត្ថ** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ខាវ ចាន់ដេត** | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤- ឯកឧត្តម **ស៊ុយ សាន** | អគ្គាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- លោក **តឹកវ៉េត សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន ០១រូប | | សមាជិក |

**មាត្រា ៤.-**

បង្កើតក្រុមការងារអនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ហើយក្រុមការងារនេះត្រូវរាយការណ៍ និងទទួលខុសត្រូវលើការគ្រប់គ្រង និងដឹកនាំការងាររបស់ខ្លួន ចំពោះមុខរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលជាអ្នកកំណត់ទិសដៅកិច្ចការរដ្ឋបាលសម្រាប់សមាជិកក្រុមការងារអនុវត្តគម្រោង ហើយសមាជិកទាំងអស់ត្រូវបំពេញការងារដោយឯករាជ្យ អព្យាក្រឹត្យ និងរក្សាការសម្ងាត់ ដោយមិនចាំបាច់ស្វែងរក ឬទទួលការណែនាំពីខាងក្រៅ លើសេចក្តីសម្រេចកិច្ចការរដ្ឋបាលរបស់ខ្លួនឡើយ។ ក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តគម្រោងមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក **យិត បុណ្ណា** | នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស | នាយកគម្រោង |
| ២- លោក **លី បូរិន** | នាយកផ្លូវ ស្ពាន អាគារ រាជាយស្ម័យយានកម្ពុជា | ប្រធានគ្រប់គ្រងបច្ចេកទេស |
| ៣- លោក **ចាន់ សំឡេង** | នាយក ផ្លូវ ស្ពាន អាគារ រាជាយស្ម័យយានកម្ពុជា | ប្រធានគ្រប់គ្រងទូទៅ |
| ៤- លោក **ខៀវ ម៉ុនតឹក** | ប្រធានបណ្តាញផ្លូវដែកពាយ័ព្យទិស រាជាយស្ម័យយានកម្ពុជា | ទទួលបន្ទុកបណ្តាញផ្លូវដែក (ភ្នំពេញ-ប៉ោយប៉ែត) |
| ៥- លោក **ម៉េង លី** | ប្រធានទទួលបន្ទុកសិល្បការ្យ និងស្ថាបនាថ្មី រាជាយស្ម័យយានកម្ពុជា | (ភ្នំពេញ-ក្រុងព្រះសីហនុ) |

៦- លោក **អ៊ិត សំរេងសុផល** មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបន្ទុកលទ្ធកម្ម-គណនេយ្យ

៧- លោក **នឹង ម៉ារីណា** មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន ទទួលបន្ទុករដ្ឋបាល

៨- លោក **រតន៍ សាម៉ន** មន្ត្រីខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួយការរដ្ឋបាល

**មាត្រា ៥.-**

បង្កើតក្រុមការងារសម្រាប់អភិវឌ្ឍដីធ្លីអោយទទួលខុសត្រូវក្នុងការអភិវឌ្ឍដីធ្លីជាអចលនទ្រព្យរបស់រាជាយស្វ័យយានកម្ពុជា តាមរយៈការជួល ប៉ុន្តែមិនអាចផ្ទេរ ឬ លក់ដីទាំងនោះចេញពីកម្មសិទ្ធិរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈរាជាយស្វ័យយានកម្ពុជា។ ការអភិវឌ្ឍដីធ្លីនេះ មានគោលបំណងប្រមូលយកប្រាក់ចំណូលសុទ្ធដែលបានពីការអភិវឌ្ឍ ដើម្បីទូទាត់ថ្លៃចំណាយបន្ថែមដែលមិនបានគ្រោងទុក និងប្រើជាដើមទុនសម្រាប់ការសាងសង់បណ្តាញផ្លូវដែកនាពេលអនាគត។ ក្រុមការងារសម្រាប់អភិវឌ្ឍដីធ្លី មានសមាសភាពដូចខាងក្រោមនេះ:

១- ឯកឧត្តម **សុខុម គគទន្តមុនី** ប្រធានអគ្គនាយករាជាយស្វ័យយានកម្ពុជា ប្រធាន

២- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៤- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥- តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦- លោក **ស៊ូ ផល្លី** នាយករងរដ្ឋបាល រាជាយស្វ័យយានកម្ពុជា សមាជិក

៧- លោក **នៅ ឌីណា** បុគ្គលិករាជាយស្វ័យយានកម្ពុជា សមាជិកអចិន្ត្រៃយ៍

## ជំពូកទី ៣

## តួនាទី និងភារកិច្ច

**មាត្រា ៦.-**

គណៈកម្មាធិការតម្រង់ទិសគម្រោងមានភារកិច្ច ពិនិត្យ សម្របសម្រួល និងផ្តល់អនុសាសន៍ទាក់ទងនឹងការអនុវត្តគម្រោង តាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦។

**មាត្រា ៧.-**

ក្រុមការងារគ្រប់គ្រងសម្បទាន មានភារកិច្ចពិនិត្យ និងវាយតម្លៃលើឯកសារលទ្ធកម្ម ដើម្បីផ្តល់សម្បទានដល់ប្រតិបត្តិករដែលជាក្រុមហ៊ុនឯកជនធ្វើអាជីវកម្មលើបណ្តាញផ្លូវដែកកម្ពុជា ដែលបានស្តារ ជួសជុលរួចក្រោមគម្រោងនេះ និងដំណើរការការងាររបស់ខ្លួនដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព. គណនេយ្យភាព និងធ្វើការតាមដានត្រួតពិនិត្យកិច្ចសន្យាសម្បទាន និងការគោរពតាមលក្ខខ័ណ្ឌសុខភាព សុវត្ថិភាពពលកម្ម និងបរិស្ថានរបស់ប្រតិបត្តិករ ហើយធ្វើរបាយការណ៍ពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីពិនិត្យ និងធ្វើការងារតាមសមត្ថកិច្ច។

**មាត្រា ៨.-**

ក្រុមការងារសម្រាប់អនុវត្តគម្រោង មានភារកិច្ចអនុវត្ត និងគ្រប់គ្រងការអនុវត្តគម្រោង រាប់បញ្ចូលទាំងការងារលទ្ធកម្ម សាងសង់ និងការដកប្រាក់កម្ចី និងធ្វើរបាយការណ៍សកម្មភាពរបស់ខ្លួនជូនធនាគារអភិវឌ្ឍន៍អាស៊ី និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាព ហើយអនុលោមតាមល័ក្ខខ័ណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦។

**មាត្រា ៩.-**

ក្រុមការងារអភិវឌ្ឍន៍ដីធ្លី មានភារកិច្ចធ្វើការអភិវឌ្ឍអចលនទ្រព្យរបស់រាជាយស្ម័យយានកម្ពុជា សម្រាប់បម្រើគោលបំណង និងគោលដៅ ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាព និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈរាជាយស្ម័យយានកម្ពុជា។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ១០.-**

គណៈកម្មាធិការតម្រង់ទិសគម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

**មាត្រា ១១.-**

អង្គភាពគ្រប់គ្រងសម្បទាន និងក្រុមការងារអនុវត្តនីតិគម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ១២.-**

ក្រុមការងារអភិវឌ្ឍន៍ដីធ្លី ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់រាជាយស្វ័យយានកម្ពុជា។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

អនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងថវិកាកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៤*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*